# កិច្ចតែងការបង្រៀន

- កាលបរិច្ឆេទ ៖ ថ្ងៃចន្ទ ៧កើត ខែ ភទ្របទ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
  ត្រូវនិងថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០២៤
- ថ្នាក់កម្រិត ៖ មធ្យម
- មុខវិជ្ជា ៖ វិទ្យាសាស្ត្រ
- ប្រធានបទ ៖ ការស្គាល់ពីវប្បធម៌ខ្មែរ
- សកម្មភាពគោល ៖ សង្កេត
- ចំណងជើងមេរៀន ៖ ទង់ព្រះពុទ្ធសាសនា
- រយៈពេល ៖ ៣០ នាទី

I. **វត្ថុបំណង**

- វិជ្ជាសម្បទា ៖ កុមារប្រាប់បានពីលក្ខណៈ រូបរាង ស្គាល់ពណ៌ ចំនួនពណ៌នៅលើទង់ព្រះពុទ្ធសាសនា និងអត្ថន័យ បានត្រឹមត្រូវតាមរយៈការ ណែនាំរបស់គ្រូ។
- បំណិនសម្បទា ៖ កុមារកំណត់បានពីលក្ខណៈ រូបរាង ស្គាល់ពណ៌ ចំនួនពណ៌នៅលើទង់ព្រះពុទ្ធសាសនា និងអត្ថន័យ បានត្រឹមត្រូវតាមរយៈការសង្កេតផ្ទាល់។
- ចរិយាសម្បទា ៖ បណ្តុះភាពឈ្លាសវៃ រហ័សរហួន ស្គាល់ពីវប្បធម៌ខ្មែរ និងប្រពៃណី បានត្រឹមត្រូវ។

II. **សម្ភារៈឧបទេស និងការរៀបចំ**

- សម្ភារៈឧបទេស
  - សម្ភារៈគ្រូ ៖ ផ្ទាំងរូបភាពទង់ព្រះពុទ្ធសាសនា
  - សម្ភារៈកុមារ ៖ គ្មាន
- ការរៀបចំ
  - ទីកន្លែង ៖ ក្នុងថ្នាក់រៀន
  - ការរៀបចំ ៖ អង្គុយជារៀងអក្សរ អ៊ុយ (U)
- គោលវិធី ៖ សិស្សមជ្ឈមណ្ឌល

III. **ដំណើរការបង្រៀន**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| -តើកូនៗមកជុំគ្នាហើយឬនៅកូន ?<br><br>-តើពេលចេញលេងមុននេះកូនៗមានបានលេងដីដែរ ឬ ទេ ? | ជំហានទី១<br>*លំនឹងថ្នាក់<br><br>-វត្តមាន/អវត្តមាន<br><br>-អនាម័យ | -ជម្រាបអ្នកគ្រូ មកជុំគ្នាហើយ<br><br>-ជម្រាបអ្នកគ្រូអត់បានលេងទេ |

| | | |
|---|---|---|
| -តើកូនល្អគេអង្គុយយ៉ាងមិចកូន?<br>-ឥឡូវកូនក្រោកឈរឡើងច្រៀងបទ ៖ មេអំបៅទៅសាលាទាំងអស់គ្នាណា | -សណ្តាប់ធ្នាប់<br>-ការប្រមូលអារម្មណ៍ | -ជម្រាបអ្នកគ្រូ គេអង្គុយដាក់ដៃលើភ្លៅ<br>-ក្រោកឈរច្រៀងទាំងអស់គ្នា |
| | ជំហានទី២ | |
| -តើកាលពីសប្តាហ៍មុនអ្នកគ្រូបានបង្រៀនវិទ្យាសាស្ត្រ អ្វីដល់កូន? | *ត្រួតពិនិត្យមេរៀនចាស់<br>-វិទ្យាសាស្ត្រៈ សង្កេតៈ រូបភាព ទង់ជាតិខ្មែរ | -កុមារឆ្លើយ |
| -តើនៅពេលកូនទៅវត្ត កូនធ្លាប់បានឃើញទង់ដែលមានពណ៌ចម្រុះច្រើនដែរឬទេកូន? | *ទំនាក់ទំនងមេរៀនថ្មី<br>-ទង់ព្រះពុទ្ធសាសនា | -ធ្លាប់ /មិនធ្លាប់ |
| | ជំហានទី៣<br>*មេរៀនថ្មី៖វិទ្យាសាស្ត្រៈសង្កេត ទង់ព្រះពុទ្ធសាសនា | |
| -កូនបិទភ្នែកអ្នកគ្រូមានរបស់ចង់ឲ្យកូនមើលណាៈនេះនែតើជារូបអ្វីកូន? | -បង្ហាញសម្ភារៈ៖រូបភាពទង់ព្រះពុទ្ធសាសនា | -មើល ឆ្លើយ |
| -ថ្ងៃនេះអ្នកគ្រូមានមេរៀនថ្មីមកបង្រៀនកូនគឺ វិទ្យាសាស្ត្រ ៖ សង្កេតៈ ទង់ព្រះពុទ្ធសាសនា | -ប្រាប់ចំណងជើងមេរៀនថ្មី | -ស្តាប់ |
| -កូនៗថាតាមអ្នកគ្រូទាំងអស់គ្នាណា | -អានចំណងជើងមេរៀន | -អានតាមគ្រូ |
| -តើកូនៗបានឃើញអ្វីខ្លះនៅលើរូបទង់សាសនានេះកូន? | -មានពណ៌ ខៀវ លឿង ក្រហម ស ហង្សបាទ និងពណ៌ផ្លេក | -កុមារឆ្លើយ មានពណ៌ ខៀវ លឿង ក្រហម ស ...... |
| -ចុះកូនធ្លាប់ឃើញទង់ព្រះពុទ្ធសាសនានេះនៅឯណាដែរកូន? | -នៅវត្តអារាម | -នៅវត្ត |
| -ចា! ទង់ព្រះពុទ្ធសាសនាយើងមានពណ៌ ដូចជា៖ ពណ៌ ខៀវ ពណ៌លឿង ពណ៌ ក្រហម ពណ៌ស ពណ៌ហង្សបាទ និងពណ៌ផ្លេក | -សម្គាល់ពណ៌ នៅលើទង់ព្រះពុទ្ធសាសនាខ្មែរ | -មើល និងស្តាប់ |
| -កូនដឹងទេថាពណ៌នីមួយៗនៅលើទង់ព្រះពុទ្ធសាសនាយើងខ្មែរយើងគឺសុទ្ធតែមានអត្ថន័យផ្សេងៗពីគ្នាណា៖<br>*ពណ៌ ខៀវ គឺកាលព្រះអង្គសោយជាតិជាព្រះបាទស្រីភិរាស្ត្រ ទ្រង់បានបរិច្ចាកព្រះនេត្រឲ្យឥន្ទព្រាហ្មណ៍<br>*ពណ៌ លឿង គឺកាលព្រះអង្គសោយជាតិជាវិនីបណ្ឌិតទ្រង់បានអារសាច់បិត | -អត្ថន័យតាមពណ៌នៅលើទង់ព្រះពុទ្ធសាសនា<br>*ពណ៌ ខៀវ គឺកាលព្រះអង្គសោយជាតិជាព្រះបាទស្រីភិរាស្ត្រ ទ្រង់បានបរិច្ចាកព្រះនេត្រឲ្យឥន្ទព្រាហ្មណ៍<br>*ពណ៌ លឿង គឺកាលព្រះអង្គសោយជាតិជាវិនីបណ្ឌិតទ្រង់បានអារសាច់បិត<br>ព្រះពុទ្ធរូប | -មើល និងស្តាប់ |

| | | |
|---|---|---|
| ព្រះពុទ្ធរូប<br>*ពណ៌ ក្រហម គឺកាលព្រះអង្គសោយជាតិជាបទុមមាណពទ្រង់បានបរិច្ចាកបេះដូងព្យាបាលមាតា<br>*ពណ៌ ស គឺកាលព្រះអង្គសោយជាតិជាព្រះវេសន្តរទ្រង់បានបរិច្ចាកស្តេចដំរី ស ឲ្យពួកព្រាហ្មណ៍<br>*ពណ៌ ហង្សបាទ គឺកាលព្រះអង្គសោយជាតិជា វិជ្ជាធរ ទ្រង់បានអារសាច់ឲ្យយក្សដើម្បីជួយមាតា<br>*ពណ៌ ផ្លេក គឺកាលព្រះអង្គសោយជាតិជាទន្សាយសោមបណ្ឌិតទ្រង់បានបូជាព្រះកាយលោតចូលភ្លើងធ្វើជាអាហារឲ្យព្រះឥន្ទ | *ពណ៌ ក្រហម គឺកាលព្រះអង្គសោយជាតិជាបទុមមាណពទ្រង់បានបរិច្ចាកបេះដូងព្យាបាលមាតា<br>*ពណ៌ ស គឺកាលព្រះអង្គសោយជាតិជាព្រះវេសន្តរទ្រង់បានបរិច្ចាកស្តេចដំរី ស ឲ្យពួកព្រាហ្មណ៍<br>*ពណ៌ ហង្សបាទ គឺកាលព្រះអង្គសោយជាតិជា វិជ្ជាធរ ទ្រង់បានអារសាច់ឲ្យយក្សដើម្បីជួយមាតា<br>*ពណ៌ ផ្លេក គឺកាលព្រះអង្គសោយជាតិជាទន្សាយសោមបណ្ឌិតទ្រង់បានបូជាព្រះកាយលោតចូលភ្លើងធ្វើជាអាហារឲ្យព្រះឥន្ទ | |
| -ទង់ព្រះពុទ្ធសាសនានេះសំខាន់ណាស់សម្រាប់ ព្រះពុទ្ធសាសនាខ្មែរយើងសព្វថ្ងៃនេះណាកូន ដូច្នេះកូនៗត្រូវចេះស្រឡាញ់ និងចូលរួមថែរក្សា ប្រពៃណី ជាតិ សាសនារបស់ខ្មែរយើងឲ្យបានគង្សវង់តរៀងទៅ | -ប្រាប់ពីសារៈសំខាន់ និងបណ្តុះស្មារតីកុមារឲ្យចេះស្រឡាញ់ វប្បធម៌ ប្រពៃណី ជាតិ សាសនា ខ្មែរ | -ស្តាប់គ្រូ |
| | ជំហានទី៤<br>*ពង្រឹងចំណេះដឹង | |
| -តើមុននេះអ្នកគ្រូបានបង្រៀនវិទ្យាសាស្ត្រអ្វីដល់កូនៗទាំងអស់គ្នា? | -វិទ្យាសាស្ត្រះសង្កេត ទង់ព្រះពុទ្ធសាសនា | -កុមារម្នាក់ឆ្លើយ |
| -កូនណាអាចឡើងមកឡើរៀបរាប់ពណ៌នៅលើទង់ព្រះពុទ្ធសាសនាឡើងវិញឲ្យមិត្តភក្តិយើងស្តាប់ម្តងទៀតបានកូន | -កុមាររៀបរាប់ពណ៌ឡើងវិញ ១ឬ២នាក់ | -កុមាររៀបរាប់ពណ៌ឡើងវិញ១ឬ២នាក់ |
| | ជំហានទី៥<br>*ការសរសើរ និងលើកទឹកចិត្ត | |
| -អ្នកគ្រូសប្បាយចិត្តណាស់ដែលឃើញកូនៗមានភាពវៃឆ្លាត និងយកចិត្តទុកដាក់នៅពេលរៀនសូត្រអញ្ជឹង | -កុមារមានភាពសប្បាយរីករាយ | -សប្បាយចិត្ត |
| | *បណ្តាំផ្ញើ និងកិច្ចការផ្ទះ | |
| -ពេលត្រឡប់ទៅផ្ទះវិញកូនកុំភ្លេចប្រាប់ប៉ាម៉ាក់ថាកូនបានរៀន វិទ្យាសាស្ត្រះសង្កេតទង់ព្រះពុទ្ធសាសនាផងណាកូន | -កុមារស្តាប់ដោយយកចិត្តទុកដាក់ | -កុមារស្តាប់ដោយយកចិត្តទុកដាក់ |

មតិយោបល់....................................                                    ថ្ងៃ ចន្ទ ទី ០៩ ខែ កញ្ញា ឆ្នាំ ២០២៤

..........................................................                                    គ្រូប្រចាំថ្នាក់

........................................................

..........................................................។                                    ឈាន សុខមឿន

បានពិនិត្យត្រឹមត្រូវ

ថ្ងៃ.....................ទី...........ខែ................ឆ្នាំ.......

នាយិកាសាលា